Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 4/2 (July 2003): 16–19

# Pastors, Fathers, and Shepherds: Models of the Kingdom



*Glenn MILES*

I find the picture of the shepherd in scripture to be very comforting. Jesus is the Good Shepherd.[1] He knows the sheep by name and leads them.[2] He will actively seek out the lost sheep to bring it home.[3] He is so committed that he is prepared to die for the sheep.[4]

Jesus charged Peter with the responsibility of shepherding the lambs and sheep as a demonstration of his love for his Lord.[5] As pastors and leaders in the church, and as fathers of our families, we are required to do the same. Isn't it interesting that Jesus mentions lambs before the sheep, surely as a reminder of God's priority for children?

---

[1]Jn 10:1–18; Lk 15:3–7.
[2]Jn 10:4.
[3]Lk 15:3–7.
[4]Jn 10:11.
[5]Jn 21:15–17.

In 1 Peter 5:2 we are asked to "be shepherds of God's flock that is under your care." As we would expect, youth are encouraged to submit to elders, but the verse teaches that "All of you (meaning youth *and* elders) are expected to "clothe yourselves with humility." Elders cannot be humble unless they listen to their flock. Shepherds are asked to be "not greedy for money but eager to serve; not lording it over those entrusted to you but ... examples to the flock."

That most familiar psalm, the twenty-third, is also a tribute to God as our shepherd—leading, restoring, guiding, anointing. The rod and staff are seen as comforters. It is better to have the shepherd's staff directing us than to be left vulnerable and without direction.

And yet Proverbs 13:24 ("He who spares the rod hates his son, but he who loves him is careful to discipline him") and 29:15 ("The rod of correction imparts wisdom but a child left to himself disgraces his mother") are often used as an excuse to use a stick to beat a child. If these passages are understood in the light of a shepherd's rod, a different picture emerges of discipline, guidance, and nurture.

In a country that has experienced so much violence, it may be difficult for us to realize that discipline is not the same as violence, but we must remember that God is a God of grace and forgiveness.

I also find it interesting that the sheep need to listen to Jesus' voice so that they can follow him.[6] As pastors and leaders, we will also have many who will listen to our voice so they can follow us. Does what we say echo the voice of the Good Shepherd, or do we speak with our own harsh voices?

The Old Testament warns shepherds who only take care of themselves. "You have not strengthened the weak or healed the sick or bound up the injured. You have not brought back the strays or searched for the lost. You have ruled them harshly and brutally."[7] Thankfully God himself intervenes and cares for the sheep by searching for the strays, binding up the injured, and strengthening the weak, but promises to destroy the "sleek and strong," concluding "I will shepherd the flock with justice."[8]

---

[6]Jn 10:3–4.

[7]Ezek 34:4.

Perhaps you yourself have been the victim of another's harshness or brutality either physically or emotionally? In an anonymous survey at a recent provincial EFC pastors' conference, out of eighty-four responses, two individuals admitted to having been raped and twenty-two to having been beaten by their parents as a child. Five people felt it was less serious or not serious for a child aged twelve years to be touched on the genitals by an adult. Twenty-six felt it was less serious or not serious for parents to beat their children. I believe that these figures are causes of concern in view of our call as pastors, leaders, and fathers to be shepherds.

Abuse of children is something God cannot tolerate.[9] We are called first to feed and nurture his lambs, and then to provide guidance and discipline. We are also called to be examples. This is where there can be a problem. Children who experience violence themselves are more likely to abuse their children when they become adults. They have poor role models and do not see violence as wrong, and so the cycle repeats itself.

Can you see how things repeat themselves from grandparent to parent to child? The cycle can only be broken when an adult chooses to stop using violence, and instead explores non-violent ways to discipline. Then the child experiences a different way. Patterns are difficult to change, but with God's love, grace, and healing, change is possible.

This is the same for pastors who have experienced abusive leadership themselves. They must also choose to do something different and become themselves examples of the Good Shepherd.[10]

For those of us who have experienced the consequences of abuse, what could be more hopeful than the picture of the lion lying down with the lamb in Isaiah 11:6?

But in the meantime, those of us in leadership must lose no time in "strengthening the weak, healing the sick, and binding up the

---

[8] Ezek 34:16.

[9] Lk 17:2.

[10] 1 Pet 5:3.

injured" lambs and "bringing back the strays and searching for the lost" even where we may have driven them away. Then "when the Chief Shepherd appears you will receive the crown of glory that will never fade away."[11]

[11] 1 Pet 5:4.

សំណុំឱកឃ្មុំ ៤/២ (កក្កដា ២០០៣)៖ ២០-២៥

# គ្រូគង្វាល ឪពុក និង អ្នកគង្វាលៈ គំរូនៃនគរព្រះ



*លោក គ្លេន ម៉ែល*

ខ្ញុំយល់ឃើញថា រូបភាពពីអ្នកគង្វាលដែលបទគម្ពីរបានពិពណ៌នានោះ គឺគួរជាទីកក់ក្តៅមែនទែន ។ ព្រះយេស៊ូគឺជាអ្នកគង្វាលដ៏ល្អ[១] ។ ព្រះអង្គស្គាល់ឈ្មោះចៀម ហើយព្រះអង្គដឹកនាំចៀមទាំងអស់នោះ[២] ។ ព្រះអង្គនឹងស្វែងរកចៀមណាដែលបាត់បង់ ហើយនាំយកចៀមនោះត្រឡប់មកផ្ទះវិញ[៣] ។ ព្រះអង្គបានប្តេជ្ញាចិត្តជាស្រេចរួចទៅហើយថា ព្រះនឹងព្រមសុគតជំនួសចៀម[៤] ។

ព្រះយេស៊ូបានផ្តល់នូវការទទួលខុសត្រូវឲ្យលោកពេត្រុស ក្នុងការមើលថែកូនចៀម ហ្វូងចៀម ដើម្បីស្តែងឲ្យឃើញពីសេចក្តីស្រឡាញ់របស់គាត់ដែល

---

[១] *យ៉ូហាន ១០:១-៨;លូកា ១៥:៣-៧*

[២] *យ៉ូហាន ១០:៤*

[៣] *លូកា ១៥:៣-៧*

[៤] *យ៉ូហាន ១០:១១*

គាត់មានចំពោះព្រះជាម្ចាស់[៥] ។ ក្នុងនាមជាគ្រូគង្វាល និងជាអ្នកដឹកនាំក្រុមជំនុំនៅក្នុងព្រះវិហារ និងក្នុងនាមជាឪពុកដែលជាប្រមុខដឹកនាំនៅក្នុងគ្រួសាររបស់យើងនោះ យើងក៏តម្រូវឲ្យធ្វើការដូចជាអ្នកគង្វាលហ្វូងចៀមនោះដែរ ។ តើយើងមិនចាប់អារម្មណ៍ទេឬអី ដែលព្រះយេស៊ូមានបន្ទូលពីការថែកូនចៀមមុនមើលថែចៀម ពិតប្រាកដណាស់ ដែលព្រះជាម្ចាស់រំលឹកយើងឲ្យយើងដឹងពីអាទិភាពទីមួយរបស់ព្រះជាម្ចាស់នោះ គឺការថែទាំដល់កុមារ?

នៅក្នុងគម្ពីរ ១ពេត្រុស៥:២ បានចែងថា ព្រះបានត្រាស់ហៅយើងឲ្យមកធ្វើជា "អ្នកថែរក្សាហ្វូងចៀមរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានដាក់ឲ្យឋិតនៅក្រោមការថែទាំរបស់យើង" ។ ដូចដែលយើងបានសង្ឃឹមទុកជាមុនថា យុវជនត្រូវបានគេជំរុញលើកទឹកចិត្តឲ្យចុះចូលជាមួយនឹងចាស់ទុំ ប៉ុន្តែខគម្ពីរបង្រៀនយើងថា "អ្នករាល់គ្នា (មានន័យថាទាំងយុវជន និងចាស់ទុំ) តម្រូវឲ្យ "ចេះបន្ទាបខ្លួន" ។ ចាស់ទុំមិនអាចបន្ទាបខ្លួនបានទេ ដរាបណាពួកគេព្រមស្តាប់តាមក្រុមជំនុំរបស់ខ្លួន ។ គេបានសុំឲ្យពួកអ្នកគង្វាល "កុំឲ្យមានចិត្តលោភចង់បានកំរៃ ប៉ុន្តែឲ្យយកចិត្តទុកដាក់ក្នុងការបំរើវិញ មិនមែនឲ្យមកធ្វើជាចៅហ្វាយទេ តែឲ្យមកធ្វើជាគំរូដល់ក្រុមជំនុំវិញ" ។

បទគម្ពីរទំនុកតម្កើងដែលយើងធ្លាប់ដឹងគ្រប់គ្នា ត្រង់ជំពូក២៣ ក៏បានចែងពីលក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ថា ព្រះអង្គជាអ្នកគង្វាលរបស់យើង ព្រះអង្គដឹកនាំយើង កែព្រលឹងយើង កែតម្រង់ផ្លូវយើង ចាក់ប្រេងតាំងឲ្យយើង ។ ព្រនង់ហើយនិងដំបងរបស់ព្រះអង្គ យើងមើលឃើញថា ជារបស់កំសាន្តចិត្តយើងទៅវិញ ។ វាជាការប្រសើរដែលមានដំបងរបស់អ្នកគង្វាលដឹកនាំយើង ជាជាងទុកឲ្យយើងនៅវង្វេងនាកណ្តោចកណ្តែងគ្មានទីដៅ ។

[៥] យ៉ូហាន ២១:១៥-១៧

តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងគម្ពីរសុភាសិត១៣:២៤ ("អ្នកណាដែលមិនប្រើរំពាត់(ព្រនង់ដំបង) នោះឈ្មោះថា ស្អប់កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយផ្ចាលវា") និងនៅជំពូក២៩:១៥ ("រំពាត់ និងសេចក្តីប្រដៅ រមែងឲ្យកើតមានប្រាជ្ញា តែកូនណាដែលបណ្តោយឲ្យប្រព្រឹត្តតាមអំពើចិត្ត នោះតែងធ្វើឲ្យម្តាយមានសេចក្តីខ្មាសវិញ") ត្រង់កន្លែងនេះគេតែងលើកយកមកជាការដោះសាដើម្បីយកដំបងមកវាយដំកុមារ ។ បើសិនជាខគម្ពីរត្រង់កន្លែងនេះ គេបានយល់ច្បាស់ពីដំបងរបស់អ្នកគង្វាលនោះ គេនឹងយល់ពីរូបភាពនៃការប្រដៅតម្រង់ ការដឹកនាំ បង្ហាញផ្លូវ និងការថែបំប៉ន ។

នៅក្នុងប្រទេសដែលមានបទពិសោធន៍ចំពោះអំពើហឹង្សាច្រើនជ្រុលនោះ គឺមានការពិបាកសំរាប់យើង ដើម្បីឲ្យយើងយល់ឃើញថា ការប្រដៅតម្រង់នោះមិនមែនដូចគ្នានឹងអំពើហឹង្សានោះឡើយ ប៉ុន្តែយើងត្រូវចងចាំថា ព្រះជាម្ចាស់ជាព្រះដែលមានព្រះហឫទ័យប្រណីសន្តោស(ព្រះគុណា) និងការពោរពេញទៅដោយការអត់ទោសបាប ។

ខ្ញុំក៏បានដឹងរឿងមួយគួរឲ្យចាប់អារម្មណ៍ពីចៀម គឺថាចៀមត្រូវតែស្តាប់ព្រះសូរសៀងរបស់ព្រះយេស៊ូ ធ្វើដូច្នេះទើបចៀមអាចដើរតាមព្រះអង្គបាន[៦] ។ ក្នុងនាមជាគ្រូគង្វាល និងជាអ្នកដឹកនាំ យើងក៏នឹងមានមនុស្សជាច្រើនដែលត្រូវស្តាប់សម្លេងរបស់យើង ទើបគេអាចដើរតាមយើងបាន ។ តើអ្វីដែលយើងនិយាយនោះយកតំរាប់តាមសំនៀងរបស់អ្នកគង្វាលដ៏ល្អ ឬក៏យើងនិយាយដោយប្រើសម្លេងទ្រគោះបោះបោករបស់យើងផ្ទាល់?

គម្ពីរសញ្ញាចាស់បានព្រមានចំពោះអ្នកគង្វាលទាំងឡាយណា ដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ។ "អ្នកមិនបានជួយពង្រឹងដល់ពួកអ្នកខ្សោយ ឬមិនបានជួយព្យាបាលដល់អ្នកឈឺ ឬជួយរុំរបួសដល់អ្នករងរបួសឡើយ ។ អ្នកមិន

---

[៦] *យ៉ូហាន ១០:៣-៤*

បាននាំចៀមដែលវង្វេងឲ្យវិលត្រឡប់មកវិញ ឬក៏មិនបានដើរស្វែងរកចៀមដែលបាត់នោះឲ្យឃើញវិញដែរ ។ អ្នកបែរទៅជាគាបសង្កត់ និងប្រើអំពើព្រៃផ្សៃដាក់គេទៅវិញ ។"[៧] អរព្រះគុណព្រះជាម្ចាស់ ព្រះអង្គធ្វើអន្តរាគមន៍ក្នុងការជួយថែរក្សាដល់ចៀម ដោយព្រះអង្គស្វែងរកចៀមដែលវង្វេង រុំរបួសឲ្យចៀមដែលរងរបួស និងជួយពង្រឹងកម្លាំងចៀមដែលទន់ខ្សោយ តែព្រះអង្គសន្យានឹងបំផ្លាញសត្វណាដែលធាត់ និងមានកម្លាំង" សារុបសេចក្តីមក "អញនឹងឃ្វាលវា ដោយសេចក្តីយុត្តិធម៌វិញ"[៨] ។

ប្រហែលជាលោកអ្នកផ្ទាល់បានទទួលរងនូវការប្រព្រឹត្តិបែបមិនគួរសមពីអ្នកដទៃ ឬទទួលរងនូវអំពើព្រៃផ្សៃទាំងខាងផ្លូវកាយ ឬផ្លូវចិត្តផងក៏មិនដឹង? យោងតាមការស្ទង់មតិអនាមិកនៅក្នុងពេលថ្មីៗនេះ នៅឯសន្និសីទគ្រូគង្វាលនៅតាមខេត្តរបស់ប្រ៊ីយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជា ក្នុងចំណោមចម្លើយដែលបានឆ្លើយមកប្រាប់យើងទាំងអស់មាន៨៤ នោះមានពីរករណីដែលបានបង្ហាញថាទទួលរងនូវការចាប់រំលោភ និងមាន២២ករណីដែលបានទទួលរងនូវការវាយដំពីឪពុកម្តាយរបស់គេកាលពីនៅវ័យជាកុមារ ។ មានមនុស្សប្រាំនាក់ដែលគិតថា មិនមែនជាបញ្ហាធ្ងន់ធ្ងរ ឬមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេចំពោះមនុស្សដែលពេញវ័យយកដៃទៅប៉ះពាល់ចំកន្លែងភេទរបស់ក្មេង ដែលមានអាយុ១២ឆ្នាំនោះ ។ មនុស្សចំនួន២៦នាក់បានបង្ហាញពីការយល់ឃើញរបស់ខ្លួនថា មិនមែនជាបញ្ហាធ្ងន់ធ្ងរ ឬមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេ ចំពោះឪពុកម្តាយដែលវាយដំកូនចៅរបស់គេនោះ ។ ខ្ញុំជឿថា តួលេខទាំងនេះ គឺធ្វើឲ្យយើងចាប់អារម្មណ៍ដល់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះយើង ក្នុងការធ្វើជាគ្រូគង្វាល អ្នកដឹកនាំ និងជាឪពុកដែលត្រូវយកគំរូតាមអ្នកគង្វាល ។

---

[៧] *អេសេគាល ៣៤:៤*

[៨] *អេសេគាល ៣៤:១៦*

ការរំលោភបំពានលើកុមារ គឺជាអំពើមួយដែលព្រះជាម្ចាស់មិនអាចអត់ឱនឲ្យបានឡើយ[៩] ។ ព្រះជាម្ចាស់ត្រាស់ហៅយើងមកជាដំបូង គឺឲ្យយើងឲ្យចំណីនិងមើលថែដល់កូនចៀមរបស់ព្រះអង្គ ហើយបន្ទាប់មកឲ្យយើងផ្តល់នូវការណែនាំ និងការប្រដៅតម្រង់ ។ ព្រះជាម្ចាស់ក៏ត្រាស់ហៅយើងមក ឲ្យធ្វើជាគំរូដល់គេផងដែរ ។ ត្រង់នេះឯងអាចបណ្តាលឲ្យមានបញ្ហា ។ ចំពោះកុមារដែលបានទទួលរងនូវអំពើហឹង្សា កុមារនោះឯងនៅពេលដែលគេធំឡើង គេនឹងប្រព្រឹត្តអំពើហឹង្សានេះដាក់កូនរបស់គេដែរ ។ គេមានគំរូមិនល្អ និងមិនបានយល់ថា អំពើហឹង្សាជាអំពើខុសឆ្គងនោះឡើយ ហេតុដូច្នេះហើយ អំពើនោះវានឹងវិលចុះវិលឡើងគ្មានទីបញ្ចប់ឡើយ ។

តើលោកអ្នកឃើញពីរបៀបដែលទម្លាប់របស់ជីដូនជីតា ធ្លាក់តមកឪពុកម្តាយ ហើយពីឪពុកម្តាយធ្លាក់តមកដល់កូនឬទេ? អំពើវិលវង់នេះអាចបញ្ឈប់ទៅបាន ដរាបណាមនុស្សពេញវ័យឈប់ប្រើអំពើហឹង្សាទៅកូនរបស់ខ្លួន ហើយរកវិធីប្រដៅតម្រង់កូនតាមរបៀបមួយដែលមិនប្រើអំពើហឹង្សា ។ ពេលនោះកូនបានទទួលនូវរបៀបថ្មីមួយ ដែលប្លែកពីទម្លាប់របស់ឪពុកម្តាយរបស់គេ ។ គំរូដែលធ្លាប់ធ្វើទៅហើយនោះពិបាកនឹងប្តូរផ្លាស់ណាស់ តែដោយសារសេចក្តីស្រឡាញ់ ព្រះគុណ និងការប្រោសលោះព្រះជាម្ចាស់ នោះការប្តូរផ្លាស់នឹងអាចទៅរួចបាន ។

ទម្លាប់នេះក៏ដូចគ្នានិងពួកអ្នកមានតួនាទីជាគ្រូគង្វាល ដែលធ្លាប់តែមានការប្រើអំណាចជ្រុលហួសហេតុពេកនៅពេលដឹកនាំ ។ គេគួរតែជ្រើសរើសធ្វើអ្វីមួយដែលផ្សេងពីនោះ ហើយធ្វើឲ្យខ្លួនជាអ្នកគង្វាលដ៏ល្អ ។[១០]

---

[៩] *លូកា ១៧:២*

[១០] *១ពេត្រុស ៥:៣*

ចំពោះអស់អ្នកដែលធ្លាប់ទទួលរងនូវការរំលោភបំពាន តើមានអ្វីជារូបភាពឲ្យយល់ពីស្ថានការណ៍ទាំងនេះ ជាជាងរូបភាពសត្វតោដែលដេកជាមួយកូនចៀមដូចដែលមានចែងនៅក្នុងអេសាយ ១១:៦ នោះទេ?

ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះដែរ ចំពោះអស់អ្នកដែលនៅក្នុងជួរជាអ្នកដឹកនាំ យើងមិនត្រូវបង្វាតពេលដល់ការជួយ "ពង្រឹងផ្តល់កម្លាំងដល់អ្នកទន់ខ្សោយ ជួយព្យាបាលអ្នកឈឺ និងរុំរបួសអ្នករងរបួស" ហើយនាំអ្នកដែលវង្វេងឲ្យវិលមកវិញ និងស្វែងរកអ្នកបាត់បង់" ទោះបីជានៅពេលខ្លះគេបណ្តេញយើងចេញពីគេក៏ដោយ ។ ពេលនោះ "នៅពេលដែលមេនៃពួកអ្នកគង្វាលមកលោកអ្នកនឹងបានទទួលមកុដនៃសិរីរុងរឿង ដែលនៅជាប់អស់កល្បជានិច្ច"[១១] ។

---

[១១] ១ពេត្រុស ៥:៤